AEC Australian Electoral Commission

Khmer/ខ្មែរ

# ប្រជាមតិ

ការធ្វើប្រជាមតិសហព័ន្ធ គឺជាការបោះឆ្នោតជាតិ លើសំណួរមួយអំពីការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញគឺជាឯកសារច្បាប់គោលដែលចែងពីរបៀបគ្រប់គ្រងប្រទេសរបស់យើង។ មានការបោះឆ្នោតប្រជាមតិចំនួន 44 ដងរួចទៅហើយ ចាប់តាំងពីឆ្នាំ 1901 មក។ប្រជាមតិលើកចុងក្រោយគឺបានធ្វើឡើងជាយូរណាស់មកហើយក្នុងឆ្នាំ 1999 គឺជាង 20 ឆ្នាំកន្លងទៅនេះ។

## នរណាចាំបាច់ត្រូវបោះឆ្នោត

ពលរដ្ឋអូស្ត្រាលីទាំងអស់ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ត្រូវតែបោះឆ្នោតប្រជាមតិ។ អ្នកត្រូវតែចុះឈ្មោះ ហើយអ្នកគួរតែធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិត នៃការចុះឈ្មោះរបស់អ្នក ប្រសិនបើអ្នក៖

- បានប្តូរឈ្មោះ ឬអាសយដ្ឋានរបស់អ្នកក្នុងពេលថ្មីៗនេះ
- ចូលអាយុ 18 ឆ្នាំ ឬ
- ក្លាយជាពលរដ្ឋអូស្ត្រាលី។

សូមចូលទៅកាន់គេហទំព័រ **aec.gov.au** ឬទៅយកទម្រង់បែបបទចុះឈ្មោះមួយច្បាប់ពីការិយាល័យ AEC ណាមួយ។

## ពេលណា និងកន្លែងណាត្រូវបោះឆ្នោត

ថ្ងៃបោះឆ្នោតនឹងធ្វើឡើងនៅថ្ងៃសៅរ៍ ហើយកន្លែងបោះឆ្នោតទាំងឡាយនឹងបើកពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច នៅទូទាំងប្រទេស។

ក្រុមបោះឆ្នោតចល័តក៏នឹងធ្វើដំណើរទៅតំបន់ដាច់ស្រយាលជាច្រើន ក្នុងប៉ុន្មានសប្តាហ៍មុនថ្ងៃបោះឆ្នោត។

ប្រសិនបើអ្នកមិនអាចទៅកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោតបានទេ អ្នកអាចមានសិទ្ធិទៅបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់ ឬក៏តាមប្រៃសណីយ៍។

ព័ត៌មានលម្អិតនឹងអាចរកបាននៅតាមគេហទំព័រ **aec.gov.au** នៅពេលជិតដល់ការធ្វើប្រជាមតិ។

## របៀបបោះឆ្នោត

ការបោះឆ្នោតប្រជាមតិគឺខុសពីការបោះឆ្នោតជ្រើសតាំង។ អ្នកគ្រាន់តែបំពេញសន្លឹកឆ្នោតមួយសន្លឹកប៉ុណ្ណោះ។

សន្លឹកឆ្នោតនឹងបង្ហាញសំណួរមួយ អំពីការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញ។ ដើម្បីបោះឆ្នោត សូមសរសេរ 'yes' ប្រសិនបើអ្នកយល់ព្រម ឬ 'no' ប្រសិនបើអ្នកមិនយល់ព្រមលើការកែប្រែដែលបានស្នើឡើង។

នៅកន្លែងបោះឆ្នោត អ្នកអាចសួរមន្ត្រីជំនួយការបោះឆ្នោត មិត្តភក្តិ ឬសមាជិកគ្រួសារដើម្បីសុំជំនួយអំពីរបៀបធ្វើការបោះឆ្នោតជាផ្លូវការ។

**សូមកុំបារម្ភប្រសិនបើអ្នកបំពេញខុស។**
អ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។




សន្លឹកឆ្នោតគំរូ

សូមសរសេរ **YES** ប្រសិនបើអ្នកយល់ព្រមលើការកែប្រែដែលបានស្នើឡើង

**ឬ**




សន្លឹកឆ្នោតគំរូ

សូមសរសេរ **NO** ប្រសិនបើអ្នកមិនយល់ព្រមលើការកែប្រែដែលបានស្នើឡើង

អ្នកគួរតែសរសេរចម្លើយរបស់អ្នកជាភាសាអង់គ្លេស។

# របៀបដែលគេធ្វើការសម្រេចលទ្ធផល

ការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញ ត្រូវតែបានអនុម័តដោយសន្លឹកឆ្នោត ‘សំឡេងភាគច្រើនពីរកម្រិត’ (double majority) ជាដាច់ខាត – មានន័យថា៖

- ភាគច្រើននៃការបោះឆ្នោតផ្លូវការទូទាំងប្រទេស (ច្រើនជាង 50%) ពីគ្រប់រដ្ឋ និងដែនដីទាំងអស់ និង
- ភាគច្រើននៃការបោះឆ្នោតផ្លូវការ (ច្រើនជាង 50%) ធ្វើឡើងភាគច្រើននៃរដ្ឋផ្សេងៗ (យ៉ាងហោចណាស់បួនរដ្ឋ ក្នុងចំណោមរដ្ឋទាំងប្រាំមួយ)។

### ប្រជាមតិត្រូវបានអនុម័តនៅពេលណា




■ភាគច្រើននៃអ្នកបោះឆ្នោតទូទាំងប្រទេស (ច្រើនជាងពាក់កណ្ដាល) មកពីគ្រប់រដ្ឋ និងដែនដី បោះឆ្នោត **YES** ។

និង




■ភាគច្រើននៃអ្នកបោះឆ្នោត (ច្រើនជាងពាក់កណ្ដាល) យ៉ាងហោចណាស់បួនរដ្ឋ ក្នុងចំណោមរដ្ឋទាំងប្រាំមួយ បោះឆ្នោត **YES** ។

### ការបោះឆ្នោតប្រជាមតិមិនត្រូវបានអនុម័តទេ ពេលណា




■ភាគច្រើននៃអ្នកបោះឆ្នោតទូទាំងប្រទេស (ច្រើនជាងពាក់កណ្ដាល) មកពីគ្រប់រដ្ឋ និងដែនដី បោះឆ្នោត **NO** ។

និង / ឬ




■ភាគច្រើននៃអ្នកបោះឆ្នោត (ច្រើនជាងពាក់កណ្ដាល) យ៉ាងហោចណាស់បីរដ្ឋ បោះឆ្នោត **NO** ។

**លទ្ធផលគឺជាប់កាតព្វកិច្ច។** នេះមានន័យថា រដ្ឋាភិបាលអូស្ត្រាលីត្រូវតែធ្វើតាមអ្វីដែលអ្នកបោះឆ្នោតសម្រេច។

## ការបំបាត់ជំនឿមិនពិតអំពីប្រជាមតិ

**ជំនឿមិនពិត៖** ប្រជាមតិអាចធ្វើឡើងអំពីប្រធានបទ ឬច្បាប់ណាមួយ។
**ការពិត៖** ប្រជាមតិត្រូវបានធ្វើឡើង ដើម្បីធ្វើការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញប៉ុណ្ណោះ។

**ជំនឿមិនពិត៖** ការស្ទង់មតិអំពីច្បាប់អាពាហ៍ពិពាហ៍ ឆ្នាំ 2017 គឺជាការធ្វើប្រជាមតិ ឬប្រជាសិទ្ធិ។
**ការពិត៖** វាគឺជាការស្ទង់មតិតាមប្រៃសណីយ៍ ហើយការចូលរួមគឺជាជម្រើសរបស់ប្រជាពលរដ្ឋ។

**ជំនឿមិនពិត៖** ការបោះឆ្នោតប្រជាមតិមិនមែនជាកាតព្វកិច្ចទេ។
**ការពិត៖** អ្នកត្រូវតែបោះឆ្នោត ប្រសិនបើអ្នកជាពលរដ្ឋអូស្ត្រាលីមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។

**ជំនឿមិនពិត៖** ខ្ញុំចាំបាច់ត្រូវចុះឈ្មោះដាច់ដោយឡែក។
**ការពិត៖** ប្រសិនបើអ្នកបានចុះឈ្មោះសម្រាប់ការបោះឆ្នោតនានាហើយ អ្នកក៏បានចុះឈ្មោះសម្រាប់ការបោះឆ្នោតប្រជាមតិផងដែរ។ គ្រាន់តែធ្វើឱ្យប្រាកដថា ព័ត៌មានលម្អិតរបស់អ្នកទាន់បច្ចុប្បន្នភាពប៉ុណ្ណោះ។

**ជំនឿមិនពិត៖** ខ្ញុំអាចបោះឆ្នោតបានតាមប្រៃសណីយ៍តែប៉ុណ្ណោះ។
**ការពិត៖** អ្នកអាចបោះឆ្នោតនៅថ្ងៃនោះ ឬពិនិត្យមើលសិទ្ធិរបស់អ្នកក្នុងការបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់ ឬក៏តាមប្រៃសណីយ៍ ដោយចូលទៅកាន់គេហទំព័រ aec.gov.au នៅពេលការបោះឆ្នោតជិតចូលមកដល់។

**ជំនឿមិនពិត៖** ប្រជាមតិត្រូវការសន្លឹកឆ្នោត ‘yes’ 70% ឬច្រើនជាងនេះដើម្បីអនុម័ត។
**ការពិត៖** ការអនុម័តត្រូវធ្វើឡើងដោយមានអ្នកបោះឆ្នោតច្រើនជាង 50% មកពីគ្រប់រដ្ឋ និងដែនដី ហើយច្រើនជាង 50% នៃអ្នកបោះឆ្នោតនៅក្នុងរដ្ឋភាគច្រើន (យ៉ាងហោចណាស់បួនរដ្ឋ ក្នុងចំណោមរដ្ឋទាំងប្រាំមួយ)។ នេះគឺជា ‘សំឡេងភាគច្រើនពីរកម្រិត’ (double majority)។

## តួនាទីរបស់ AEC

AEC គឺជាអាជ្ញាធរស្របច្បាប់មួយដែលឯករាជ្យ និងមិនលំអៀង។

តួនាទីរបស់ខ្លួននៅក្នុងការធ្វើប្រជាមតិ គឺផ្តល់សេវាកម្មចុះឈ្មោះ សេវាកម្មបោះឆ្នោត និងព័ត៌មាន។

ខណៈពេលដែល AEC នឹងផ្តល់ខិតប័ណ្ណ yes/no ដល់គ្រួសារអូស្ត្រាលីនោះ សូមជ្រាបថាព័ត៌មាននៅក្នុងកញ្ចប់នេះត្រូវបានផលិតដោយរដ្ឋសភា។ ក្រៅពីការផ្តល់ខិត្តប័ណ្ណនេះ AEC មិនមានការពាក់ព័ន្ធក្នុងការធ្វើយុទ្ធនាការគាំទ្រ ឬប្រឆាំងនឹងសំណើឱ្យមានការកែប្រែចំពោះរដ្ឋធម្មនុញ្ញនោះទេ។

## ចូរឈប់ ហើយពិចារណាអំពីប្រភព

ការបោះឆ្នោតរបស់អ្នកនៅក្នុងការធ្វើប្រជាមតិនឹងជួយធ្វើការសម្រេចចិត្តដ៏សំខាន់មួយសម្រាប់ប្រទេសអូស្ត្រាលី។

នៅក្នុងអំឡុងពេលធ្វើប្រជាមតិ អ្នកអាចប្រទះឃើញព័ត៌មានដែលបំភាន់ដោយចេតនា។

ចូរឈប់សិន ពិនិត្យមើល ហើយពិចារណាអំពីប្រភពដែលអ្នកឃើញ ស្តាប់ឮ ឬអាន។ កុំឱ្យគេបំភាន់ជាមួយនឹងព័ត៌មានមិនពិតនៅក្នុងការធ្វើប្រជាមតិនេះ។

សូមចូលទៅកាន់គេហទំព័រ **aec.gov.au** ដើម្បីមើលព័ត៌មាននានាដែលអ្នកគួរដឹងអំពីការពិនិត្យមើលប្រភព។

**ពិនិត្យមើលប្រភព**
នៅក្នុងការធ្វើប្រជាមតិនាពេលខាងមុខនេះ

**aec.gov.au/translated** 1300 720 134

AEC Australian Electoral Commission

AEC23/1804

ផ្តល់សិទ្ធិអនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត ទីក្រុង Canberra
Authorised by the Electoral Commissioner, Canberra